ISSN 1560-7615 / ISBN 978-99950-52-06-5

ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៣ លេខ ២ | មេសា - មិថុនា ឆ្នាំ២០០៩ | តម្លៃ ១.៥០០រ

# សន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០០៩ "ប្រទេសកម្ពុជា និង វិបត្តិសាកលៈ ផលប៉ះពាល់ ចម្លើយជាគោលនយោបាយ និងសកម្មភាព"*



ភ្ញៀវទេសចរចូលមកប្រទេសកម្ពុជា តាមច្រកព្រំដែនប៉ោយប៉ែត

សន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជាប្រចាំឆ្នាំលើកទី៣ ដែលផ្ដោតលើប្រធានបទ "ប្រទេសកម្ពុជា និងវិបត្តិសាកលៈ ផលប៉ះពាល់ ចម្លើយជាគោលនយោបាយ និងសកម្មភាព" បានប្រារព្ធធ្វើនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី ១២ មីនា ២០០៩ ក្រោមកិច្ចសហការជាដៃគូររវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal ។ ក្នុងសុន្ទរកថាគន្លឹះបើកសន្និសីទ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់ប្រាប់ភ្ញៀវកិត្តិយសទាំង ៣៥០នាក់ថា "នេះជាព្រឹត្តិការណ៍ដ៏វិសេសមួយនៅប្រទេសកម្ពុជា ដែលជារៀងរាល់ឆ្នាំ សន្និសីទនេះបានអញ្ជើញថ្នាក់ដឹកនាំមកពីខាង រដ្ឋាភិបាល វិស័យឯកជន ស្ថាប័នស្រាវជ្រាវ សង្គមស៊ីវិល និងសហគមន៍អភិវឌ្ឍន៍អន្តរជាតិ មកជួបប្រជុំគ្នាដើម្បីពិចារណាលើសមិទ្ធផល និងអនាគតរបស់ប្រទេសកម្ពុជា ។ កាលបរិច្ឆេទ និងប្រធានបទសន្និសីទចក្ខុវិស័យនាឆ្នាំនេះ មានសារៈសំខាន់ជាពិសេស ពីព្រោះយើងកំពុងទទួលរងផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងតំបន់ និងក្នុងពិភពលោក និងកំពុងប្រឹងប្រែងដោះស្រាយវិបត្តិទាំងនេះ ។"

សន្និសីទឆ្នាំ២០០៩ រួមមានវគ្គមួយចំនួនស្ដីពី វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលៈ ផលប៉ះពាល់ដល់តំបន់យើង និងប្រទេសកម្ពុជា, ការអភិវឌ្ឍធនធានមនុស្សនៅប្រទេសកម្ពុជា - ការកសាងកំលាំងពលកម្មមានជំនាញ, ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ - ការពង្រឹងវិស័យសំខាន់ៗ ដើម្បីកំនើនទៅអនាគត ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ, អាទិភាពសំរាប់គោលនយោបាយ និងការធ្វើសកម្មភាពដោយរដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ ស្ថាប័នខាងស្រាវជ្រាវ និងគោលនយោបាយ ។

ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា ក្នុងលេខពិសេសនេះ មានចុះផ្សាយអត្ថបទនានាស្ដីពីបទបង្ហាញ និងការពិភាក្សាទាំងឡាយ នៅក្នុងសន្និសីទ ។ វិទ្យាស្ថានក៏មានចេញផ្សាយ អត្ថបទសង្ខេបចក្ខុវិស័យប្រទេសកម្ពុជា មួយឈុត ជាភាសាខ្មែរ និងអង់គ្លេសផងដែរ ។ម្យ៉ាងទៀត កម្មវិធីទាំងមូល បទបង្ហាញនានា និងឯកសារជាប់ទាក់ទងនឹងសន្និសីទទាំងអស់ មានចុះនៅក្នុងវេបសាយ របស់ CDRI ៕

* Larry Strange នាយកប្រតិបត្តិ CDRI ណែនាំបង្ហាញពីទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា លេខពិសេសនេះដែលផ្ដោតលើសន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។

## មាតិកា

ប្រទេសកម្ពុជា និងវិបត្តិសាកលៈ សន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ........ ២
វិបត្តិសាកល — ផលប៉ះពាល់ ចក្ខុវិស័យ... សំរាប់កម្ពុជា........ ៤
វិបត្តិហិរញ្ញវត្ថុសាកលៈ ផលប៉ះពាល់ក្នុងតំបន់........ ៧
ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកល លើផ្នែកវិនិយោគ និងពាណិជ្ជកម្មរបស់កម្ពុជា........ ១១
ផលប៉ះពាល់ជាសក្ដានុពលនៃវិបត្តិហិរញ្ញវត្ថុទៅលើគ្រួសារក្រីក្រ និងក្រុមងាយរងគ្រោះនៅកម្ពុជា........ ១៣
ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ — កសិកម្ម........ ១៦
វិបត្តិអាហារ និងហិរញ្ញវត្ថុ — ផលប៉ះពាល់លើវិស័យកសិកម្ម........ ១៩
ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ — ទេសចរណ៍........ ២៣
ការគ្រប់គ្រងវិបត្តិសាកល — ទេសចរណ៍នៅប្រទេសកម្ពុជា និងក្នុងតំបន់........ ២៦
ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ — ហេដ្ឋារចនាសម្ព័ន្ធ........ ២៩
ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ — អចលនទ្រព្យ........ ៣៣
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស........ ៣៦
— ស្ថានភាពក្នុងប្រទេស........ ៣៨
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI........ ៤៤

# វិបត្តិអាហារ និង ហិរញ្ញវត្ថុ — ផលប៉ះពាល់លើវិស័យកសិកម្ម និង អាទិភាពគោលនយោបាយជំរុញកំណើនកសិកម្មអំណោយផលដល់ជនក្រីក្រ

*អត្ថបទនេះ សង្ខេបចេញពីបទបង្ហាញរបស់ បណ្ឌិត ថេង វុទ្ធី[1] នៅក្នុង វគ្គទី ៣ក(១) នៃសន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។*

## និន្នាការទូទៅនៃកសិកម្មកម្ពុជា និង ផលប៉ះពាល់នៃវិបត្តិ

ក្នុងរយៈពេលបីឆ្នាំមុនពេលមានវិបត្តិហិរញ្ញវត្ថុសាកល សេដ្ឋកិច្ចកម្ពុជាកើនឡើងយ៉ាងខ្លាំង ដោយមានកំណើន ផសស ជាមធ្យមប្រហែល ១១% ។ តួលេខសរុបលើម៉ាក្រូសេដ្ឋកិច្ចកម្ពុជា មានកម្រិតខ្ពស់ទាំងអស់ ហើយកំណើនបានជាចំបងមកពីវិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ ។ ខណៈដែលឧស្សាហូបីយកម្មសេដ្ឋកិច្ចបានជឿនលឿនទៅមុខយ៉ាងច្រើន កសិកម្មនៅតែជាវិស័យមួយសំខាន់ខ្លាំងណាស់ ។ យោងតាមរបាយការណ៍ថ្មីមួយរបស់ធនាគារពិភពលោក កសិកម្មចូលរួមចំណែក ២៩% នៃ ផសស (ក្រាហ្វិក ១) និងប្រើប្រាស់ ៥៩% នៃកំលាំងពលកម្មនៅឆ្នាំ២០០៧ (ក្រាហ្វិក ២) ។ ក្នុងមួយទសវត្សរ៍កន្លងមកនេះ វិស័យកសិកម្មមានកំណើន ៤,៤% ក្នុងមួយឆ្នាំ នៅកម្ពុជា ធៀបនឹង ៤% នៅវៀតណាម និង ៣,៩% នៅឡាវ ។ កំណើននេះបានមកពីការដាំដំណាំ (ជាពិសេស ស្រូវ) និងបន្ទាប់មក ការចិញ្ចឹមសត្វ និងត្រី ។

ថ្លៃអាហារខ្ពស់ បានផ្ដល់ជាគ្រឿងលើកទឹកចិត្តដល់អ្នកបង្កើតគោលនយោបាយ កសិករ និង វិនិយោគិន នៅក្នុងប្រទេសកំពុងអភិវឌ្ឍ ឱ្យបង្កើនផលិតភាពកសិកម្ម ។ នៅកម្ពុជា កសិករ និង វិនិយោគិនបរទេស បានឆក់យកឱកាសនេះ ដោយធ្វើពិពិធកម្ម និងពង្រីកផ្ទៃដីដាំដំណាំសំរាប់នាំចេញសំខាន់ៗផ្សេងទៀតបន្ថែមលើ ដំណាំស្រូវ ដូចជា ដំឡូងឈើ កៅស៊ូ ពោត និងសណ្ដែកសៀង ជាដើម ។ នៅឆ្នាំ២០០៨ ផ្ទៃដីសំរាប់ដាំដំណាំទាំងនេះ កើនដល់ ១៨០.០០០ហិកតា សំរាប់ដំឡូងឈើ ១០៨.៧០០ហិកតា សំរាប់កៅស៊ូ ១៥៦.៧៦០ហិកតា សំរាប់ពោត ៧១.៩៣០ហិកតា សំរាប់សណ្ដែកសៀង និង ២.៥៩៣.៤០០ហិកតា សំរាប់ស្រូវ ។

ស្រូវ និង ដំណាំផ្សេងៗទៀតសំរាប់នាំចេញ បានរួមចំណែក ៥២% នៃ ផសស របស់វិស័យកសិកម្ម និង ១៤% នៃ ផសស សរុប នៅឆ្នាំ២០០៧ ។ ប៉ុន្តែ វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលកាន់តែធ្ងន់ធ្ងរ នៅឆមាសទី២ ឆ្នាំ២០០៨ បានធ្វើឱ្យទំនិញកសិកម្មធ្លាក់ថ្លៃ ។ កសិករនៅប្រទេសកំពុងអភិវឌ្ឍ ដែលបានយកប្រាក់ចំណេញទទួលបានពី ការឡើងថ្លៃផលិតផលកសិកម្មកាលពីមុនទៅវិនិយោគពង្រីកផលិតកម្ម ឥឡូវនេះទំនងមិនអាចសងបំណុលរបស់ខ្លួនបានទេ ដោយសារបរិមាណលក់ និងប្រាក់ចំណូល បានធ្លាក់ចុះ ។ ដោយហេតុថា កម្ពុជាពឹងផ្អែកលើ ទីផ្សារនាំចេញ និង វិនិយោគផ្ទាល់ពីបរទេស (FDI) ដូច្នេះ វិបត្តិសាកលអាចប៉ះពាល់ខ្លាំងដល់សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។

វិបត្តិប៉ះពាល់សេដ្ឋកិច្ចកម្ពុជាធ្ងន់ធ្ងរដល់កំរិតណា គឺអាស្រ័យលើទំហំសមាហរណកម្មនៃវិស័យជំនួញ និងហិរញ្ញវត្ថុ របស់កម្ពុជាទៅក្នុងទីផ្សារពិភពលោក ។ ដោយហេតុថា ប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាបានធ្វើសមាហរណកម្មតិចតួចទៅក្នុងទីផ្សារហិរញ្ញវត្ថុពិភពលោក ដូច្នេះប្រទេសកម្ពុជាមិនបានទទួលរងការប៉ះទង្គិចដោយផ្ទាល់ពីវិបត្តិនេះទេ ។ វិស័យធនាគារនៅកម្ពុជានៅតែមានស្ថានភាពល្អ ដោយមានសាច់ប្រាក់ទំនេរ និងប្រាក់បញ្ញើសន្សំយ៉ាងច្រើន និង មានការទុកចិត្តពីសំណាក់ប្រជាជនទៀតផង ។ ផ្ទុយទៅវិញ វិស័យជំនួញបានធ្វើសមាហរណកម្មយ៉ាងច្រើនក្នុងទីផ្សារតំបន់ និងពិភពលោក ដូច្នេះហើយក៏រងឥទ្ធិពលដោយផ្ទាល់ពីការធ្លាក់ចុះ តំរូវការ និងកំរិតថ្លៃទំនិញ ។

វិនិយោគលើទំនិញសំរាប់នាំចេញ បានផ្ដល់ការងារជាច្រើនដល់គ្រួសារអ្នកគ្មានដី ។ ដូចនេះ ការធ្លាក់ចុះ តំរូវការ និងកំរិតថ្លៃទំនិញដោយសារវិបត្តិបានជះឥទ្ធិពលធ្ងន់ធ្ងរមិនត្រឹមតែលើ ប្រាក់ចំណូលរបស់ផលិតករ និង វិនិយោគិន ប៉ុណ្ណោះទេ ប៉ុន្តែលើប្រាក់ចំណូលរបស់កម្មករ និងរបស់រដ្ឋាភិបាលទៀតផង ។

ក្រាហ្វិក ១: ផសស របស់កម្ពុជា ឆ្នាំ២០០៧




*ប្រភព: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បង្ហាញក្នុងវេទិកាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលើកទី២ ខែធ្នូ ឆ្នាំ២០០៨*

## ផលប៉ះពាល់លើពាណិជ្ជកម្មកសិកម្ម

ទំនិញនាំចូលសំខាន់ៗរបស់កម្ពុជា រួមមាន ប្រេងឥន្ធនៈ ម្ហូបអាហារ ភេសជ្ជៈ សម្ភារៈសំណង់ យានយន្ត ជីកសិកម្ម និង ថ្នាំពេទ្យ ។ នៅត្រីមាសទី២ ឆ្នាំ២០០៨ តំលៃនៃការនាំចូលបានកើនឡើង ដែលបង្ហាញពីតំរូវការខ្ពស់នូវធាតុចូលសំរាប់កសិកម្ម ដូចជា សាំង ជីកសិកម្ម និង សារធាតុគីមី ។ កំណើនវិនិយោគក្នុងវិស័យនេះ បណ្ដាលមកពីការវាយស្មានថា តំរូវការទំនិញកសិកម្ម នឹងបន្តកើនឡើង ជាពិសេស ដំឡូងឈើ និង ពោត សំរាប់ប្រើប្រាស់ក្នុងការផលិតអេតាណុល (ឥន្ធនៈអាចប្រើជំនួស ផលិតផលប្រេងកាតដែលឡើងថ្លៃខ្លាំងណាស់នៅ ទីផ្សារពិភពលោក) ។ តំលៃដ៏ខ្ពស់នៃទំនិញនាំចូលជាកត្តាចំបងមួយនៃកំណើនបន្ទុកចំណាយលើឥន្ធនៈ និងធាតុចូលដទៃទៀត (ក្រាហ្វិក ៣) ។

១ បណ្ឌិត ថេង វុទ្ធី ជាអ្នកសំរបសំរួលកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃវិទ្យាស្ថាន វបសអ ។

ក្រាហ្វិក ២: ចំណែកការងារ គិតជា %




*ប្រភព: ធនាគារពិភពលោក (២០០៩), ការរក្សាកំណើនលឿននៅក្នុងបរិយាកាសប្រឈម*

ក្រាហ្វិក ៣: ការនាំចេញនាំចូល (អត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំ)




*ប្រភព: ទីចាត់ការគយ និងរដ្ឋាករ ស្រង់ចេញដោយធនាគារជាតិនៃកម្ពុជា*

កំណើនតំរូវការពីខាងក្រៅនូវផលិតផលកម្ពុជា នៅថេររហូតដល់អំឡុងខែមិថុនា ២០០៨ ទើបមានការធ្លាក់ចុះយ៉ាងខ្លាំង ។ ការនាំចេញផលិតផលកសិកម្មបានធ្លាក់ចុះ ដោយធ្លាក់ដល់កំរិតទាបបំផុតក្នុង ២០ខែចុងក្រោយនេះ នៅត្រីមាសទី៤ ឆ្នាំ២០០៨ ។ ការធ្លាក់ចុះនូវតំលៃនៃការនាំចេញផលិតផលកសិកម្ម បណ្តាលជាសំខាន់មកពី ទំនិញកសិកម្មដែលចុះថ្លៃដោយសារវិបត្តិ ។ ការប្រែប្រួលនៃនិន្នាការអតិផរណាថ្លៃអាហារ និងឥន្ធនៈឆ្លុះបញ្ចាំងពីការធ្លាក់ចុះតំរូវការពិភពលោក ។ ទោះយ៉ាងនេះក្តី គេមិនមានភស្តុតាងគ្រប់គ្រាន់ទេសំរាប់បញ្ជាក់ថា វិបត្តិគឺជាមូលហេតុតែមួយដែលនាំឱ្យការនាំចេញទំនិញកសិកម្មធ្លាក់ចុះ ។ ជំលោះព្រំដែនរវាងកម្ពុជា-ថៃ នៅឆមាសទី២ ឆ្នាំ២០០៨ ក៏មានរួមចំណែកក្នុងការធ្លាក់ចុះការនាំចេញនេះដែរ ជាពិសេសការនាំចេញដំឡូងឈើ និង ពោត ដែលកសិករកម្ពុជាមួយចំនួនបានធ្វើកិច្ចសន្យាជាមួយពាណិជ្ជករថៃរួចហើយ ។

## ផលប៉ះពាល់លើចំណូល និងវិនិយោគក្នុងវិស័យកសិកម្ម

កំណើនតំរូវការជីវឥន្ធនៈនៅប្រទេសអភិវឌ្ឍន៍ បានបង្កើនកំរិតថ្លៃ និងតំរូវការផលដំណាំដូចជា ដំឡូងឈើ និង ពោត ជាដើម ។ រឿងនេះ ផ្តល់គ្រឿងលើកទឹកចិត្តដល់ម្ចាស់ដីតូចៗ និង វិនិយោគិន ឱ្យពង្រីកផលិតកម្ម ។ នៅកម្ពុជា ផលិតកម្មដំណាំអាហារទាំងនេះ កើនដល់ ៣,៩៧លានតោន នៅឆ្នាំ២០០៨ ធៀបនឹង ២,៨៨លានតោន នៅឆ្នាំ២០០៧ ។ ជាអកុសល ការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក បានបន្ទាបតំរូវការ និងថ្លៃទំនិញនានា ។ ឧទាហរណ៍ ថ្លៃប្រេងនាពេលបច្ចុប្បន្ន ធ្លាក់ចុះលើសពី ៦០% បើធៀបនឹងកំរិតថ្លៃខ្ពស់បំផុត នៅឆ្នាំ២០០៨ ។ ការធ្លាក់ថ្លៃនេះ បានកាត់បន្ថយតំរូវការជីវឥន្ធនៈ និង សារធាតុសំរាប់លាយបន្ថែមជាមួយឥន្ធនៈ ដូចជា អេតាណុល ជាដើម ដែលនាំឱ្យផលដំណាំសំរាប់ផលិតជីវឥន្ធនៈ ធ្លាក់ថ្លៃយ៉ាងខ្លាំង ។ បើសិនគ្មានការធ្លាក់ថ្លៃនេះទេ នៅឆ្នាំ២០០៨ ផលិតករពោត និង ដំឡូងឈើប្រហែលអាចបង្កើនប្រាក់ចំណេញដុលបានដល់ ៨២% និង ១៧៦% បើធៀបនឹង ឆ្នាំ២០០៧ ហើយប្រាក់ចំណេញដុលសំរាប់សណ្តែកសៀង ក៏ប្រហែលកើនឡើង ៤៦% ផងដែរ ។ ប៉ុន្តែដោយសារ ការធ្លាក់ថ្លៃយ៉ាងរហ័សនៃដំណាំទាំងនេះនៅឆមាសទី២ ឆ្នាំ២០០៨ ប្រាក់ចំណេញសុទ្ធលើពោត សណ្តែកសៀង និង ដំឡូងឈើ បានធ្លាក់ចុះអស់ ២៩% ៤៧% និង ១៦៦% ។ ចំណាយលើធាតុចូលសំរាប់ដំណាំទាំងនេះមានកំរិតខ្ពស់ដដែល ពីព្រោះធាតុចូលត្រូវបានប្រើប្រាស់ នៅត្រីមាសទី២ និង ទី៣ ប៉ុន្តែ ផលិតផលបានធ្លាក់ថ្លៃខ្លាំងនៅត្រីមាសទី៤ ឆ្នាំ២០០៨ ។

មុនពេលមានវិបត្តិ ផលិតកម្មដំណាំឧស្សាហកម្ម ដូចជា កៅស៊ូ ជាដើម បានផ្តល់ផលចំណេញច្រើនណាស់ ដល់ក្រុមហ៊ុនរដ្ឋ ក្រុមហ៊ុនឯកជន និង ម្ចាស់ដីតូចៗ ។ នៅខែតុលា ២០០៨ ថ្លៃកៅស៊ូនៅទីផ្សារពិភពលោកឡើងដល់ ៣២០០ដុល្លារ/តោន ប៉ុន្តែធ្លាក់ចុះមកត្រឹម ១២០០-១៣០០ដុល្លារ នៅខែធ្នូ ២០០៨ ។ វិបត្តិ បានធ្វើឱ្យការនាំចេញធ្លាក់ចុះអស់ ១៥,២% ។ នៅឆ្នាំ២០០៨ ប្រាក់ចំណេញពីដំណាំកៅស៊ូ ស្ទើរតែគ្មានសោះ ពីព្រោះផលិតកម្ម កៅស៊ូត្រូវការចំណាយ ៨០០ដុល្លារ/តោន (គ្មានបូកបញ្ចូលការប្រាក់លើកំចី ពន្ធ និង ចំណាយពាក់ព័ន្ធផ្សេងទៀត) ហើយថ្លៃកៅស៊ូនៅកម្ពុជាវាទាបជាងកំរិតថ្លៃនៅទីផ្សារពិភពលោក ប្រហែល ១៥% ។ រដ្ឋាភិបាល និងដៃគូផ្នែកឯកជន បានជួបពិភាក្សាពីការធ្លាក់ថ្លៃយ៉ាងខ្លាំងនៃជ័រកៅស៊ូ និងស្ថានភាពគួរឱ្យបារម្ភនៃផលិតកម្មកៅស៊ូ ព្រមទាំងបានពិគ្រោះពីសំណើកាត់បន្ថយប្រាក់កំរៃលើការនាំចេញ ។ ទោះយ៉ាងនេះក្តី ឯកឧត្តម បណ្ឌិត ចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឱ្យដឹងថា ផលិតកម្មកៅស៊ូ នៅតែអាចរកចំណេញបាន ពី ២% ទៅ ៣% ដែរ នៅពេលដែលរដ្ឋាភិបាល មិនទាន់បានឆ្លើយតបនឹង សំណើកាត់បន្ថយប្រាក់កំរៃលើការនាំចេញនេះ ។

ខុសប្លែកពី កៅស៊ូ ពោត និងដំឡូងឈើ ដំណាំស្រូវមិនបានរងឥទ្ធិពលខ្លាំងពីវិបត្តិទេ ។ នៅឆ្នាំ២០០៨ វិនិយោគិន លើដំណាំស្រូវប្រាំង អាចបង្កើនប្រាក់ចំណូលបាន ៣៣% បើធៀបនឹងឆ្នាំ២០០៧ ។ ប៉ុន្តែក្នុងឆ្នាំដូចគ្នា ប្រាក់ចំណូលរបស់វិនិយោគិនលើស្រូវវស្សា បានធ្លាក់ចុះ ១១% ដែលមិនមែនដោយសារស្រូវវស្សាធ្លាក់ថ្លៃនោះទេ ព្រោះវាមានថ្លៃខ្ពស់ជាងកាលពីឆ្នាំ ២០០៧ ទៅទៀត ប៉ុន្តែដោយសារ ការចំណាយខ្ពស់ជាងមុនលើធាតុចូល ។

## ផលប៉ះពាល់លើពលកម្ម

ថ្លៃទាបនៃទំនិញសំរាប់នាំចេញមួយចំនួន អាចបង្កឱ្យមានការកាត់បន្ថយវិនិយោគ និងការធ្លាក់ចុះតំរូវការពលកម្ម ។ ដូច្នេះ គ្រួសារដែលមិនមានដីធ្លី និងដែលពឹងផ្អែកខ្លាំងលើប្រាក់ឈ្នួលបានពីពលករចំណាកស្រុកខាងកសិកម្ម ទំនងត្រូវប្រឈមមុខនឹងការលំបាក ។ ពួកគេជាជនក្រីក្របំផុត ហើយវិបត្តិនឹងរុញច្រានពួកគេឱ្យធ្លាក់ខ្លួនក្រកាន់តែខ្លាំងទៀត ប្រសិនបើមិនមានការដាក់អនុវត្តប្រព័ន្ធសុវត្ថិភាពសង្គមប្រកបដោយប្រសិទ្ធភាពនោះទេ ។

## កាលានុវត្តភាព និង បញ្ហាប្រឈមចំពោះកំណើនកសិកម្ម អំណោយផលដល់ជនក្រីក្រ

បច្ចុប្បន្ននៅមានឱកាសល្អជាច្រើន ដែលអាចបន្តជួយលើកស្ទួយវិស័យកសិកម្មនៅកម្ពុជា ។ ឱកាសល្អទី១ និងសំខាន់ជាងគេ គឺតំរូវការដែលរំពឹងថានឹងនៅតែមានច្រើន ដោយគេគិតថា តំរូវការពីប្រទេសចិន ឥណ្ឌា អាហ្វ្រិក និង តំបន់មជ្ឈិមបូព៌ា នឹងកើនឡើងយ៉ាងលឿន ហើយការធ្លាក់ចុះកំរិតថ្លៃទំនិញនាពេលថ្មីៗអាចមានរយៈពេលមិនយូរទេ ។ ដោយមូលហេតុនេះ រួមនឹងឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងវិស័យកសិកម្ម (ដីធ្លីសំបូរ ពលកម្មថោក និងសក្តានុពលក្នុងការបង្កើនវិនិយោគខាងកសិកម្ម) រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា មានទំនុកចិត្តថា កសិកម្មអាចជាកត្តាគន្លឹះសំរាប់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព នៅក្នុងពេលដ៏លំបាកនេះ ។

ដោយសារវិបត្តិបានប៉ះពាល់ធ្ងន់ធ្ងរដល់ឧស្សាហកម្មកាត់ដេរ សំណង់ និងទេសចរណ៍ កម្មករជាច្រើនបានបាត់បង់ការងារ ហើយត្រូវបង្ខំចិត្តត្រឡប់ទៅធ្វើស្រែចំការនៅភូមិកំណើតវិញបើសិនមានលទ្ធភាព ។ តាមនេះ គេអាចឃើញច្បាស់ពីសារៈសំខាន់នៃវិស័យកសិកម្ម ក្នុងការផ្តល់ការងារ និងជួយទ្រទ្រង់សេដ្ឋកិច្ច នៅពេលដែល វិស័យឯទៀតស្រុតចុះ ។ សក្តានុពលមានយ៉ាងច្រើនក្នុងវិស័យកសិកម្ម ហើយដើម្បីឱ្យវាក្លាយជាការពិត គេគួរបង្កើនវិនិយោគជាសំខាន់ ។ កម្ពុជាមានលទ្ធភាពបង្កើនទិន្នផលស្រូវឱ្យស្មើគ្នានឹងប្រទេសជិតខាងបាន ប្រសិនបើកម្ពុជាមានហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យាសមស្រប ។ ប៉ុន្តែទន្ទឹមគ្នានឹងសក្តានុពល ក៏មានបញ្ហាប្រឈមធំៗមួយចំនួនដែរ (សូមមើលក្នុងប្រអប់ខាងក្រោម) ដែលត្រូវដោះស្រាយ ដើម្បីសំរេចបានកំណើនកសិកម្មអំណោយផលដល់ជនក្រីក្រ និងការកាត់បន្ថយភាពក្រីក្រ ៕

**ប្រអប់៖ បញ្ហាប្រឈមសំរាប់វិស័យកសិកម្ម***

| | |
|---|---|
| **កំណែទំរង់ការគ្រប់គ្រង និងប្រើប្រាស់ដី** | ផ្ទៃដីធំៗសំរាប់សម្បទានដីសេដ្ឋកិច្ច គួរផ្ដល់នៅកន្លែងដែលសំបូរគ្រួសារគ្មានដីធ្លី ដើម្បីបង្កើតការងារសំរាប់សមាជិកគ្រួសារទាំងនោះ ។ រដ្ឋាភិបាល គួរផ្ដោតលើគោលនយោបាយដ៏ប្រសើរមួយដើម្បីបែងចែកដីសាជាថ្មី ដល់គ្រួសារអ្នកគ្មានដីធ្លី ព្រោះអ្នកកាន់កាប់ដីតូចៗមានផលិតភាពខ្ពស់ជាងក្នុងការដាំដុះមុខដំណាំជាច្រើន ហើយគោលនយោបាយនេះមានឥទ្ធិពលខ្លាំងក្នុងការកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ច ។ បញ្ហាធំមួយទៀតនៅពេលនេះ គឺ ការចុះបញ្ជីដីធ្លី ព្រោះការទន្ទ្រានយកដីកាន់កាប់ បាននិងកំពុងគំរាមកំហែង ដល់កសិករក្រីក្រជាច្រើន ។ យុទ្ធសាស្ត្រដោះស្រាយបញ្ហានេះរួមមាន ការពង្រឹងដល់ការគោរពកម្មសិទ្ធិអចលនទ្រព្យរបស់អ្នកក្រ ការធ្វើនិត្យានុកូលកម្មការដោះដូរដែលជាប់ពាក់ព័ន្ធនឹងកម្មសិទ្ធិ និង ការជំរុញគោលនយោបាយប្រើប្រាស់ដី ឱ្យមានប្រយោជន៍ និងមានសមធម៌សំរាប់ជនគ្រប់រូប ។ |
| **ការកសាងហេដ្ឋារចនាសម្ព័ន្ធ** | របាយការណ៍របស់ធនាគារពិភពលោកឆ្នាំ២០០៩ បានឱ្យដឹងថា វិនិយោគលើធារាសាស្ត្របានផ្ដល់ផលត្រឡប់យ៉ាងច្រើន ៖ អនុបាតចំណេញ-ចំណាយ (ចំណូលបន្ថែមក្នុងមួយហិកតាផ្ទៃដីមានប្រព័ន្ធធារាសាស្ត្រ ចែកនឹងចំណាយឯកតាលើការផ្ដល់ធារាសាស្ត្រ) មានចាប់ពី ១.៥ នៅតំបន់ទន្លេសាប រហូតដល់ ១.៩ នៅតំបន់វាលទំនាប នៅឆ្នាំ២០០៤ និងកើនលើសពី ២ នៅឆ្នាំ២០០៧ ។ ដូច្នេះការកែលំអគំរោងធារាសាស្ត្រដែលមានស្រាប់ ឬ ការវិនិយោគលើធារាសាស្ត្រ វាជួយបង្កើនផលិតភាព និងចំរុះកម្ម ដំណាំដាំដុះ ។ ហេដ្ឋារចនាសម្ព័ន្ធជនបទគ្រប់គ្រាន់ និងមានប្រសិទ្ធភាព ក៏ជួយកាត់បន្ថយចំណាយផលិតកម្ម និងបង្កើនកំរិតថ្លៃនៅកសិដ្ឋានដែរ ។ ហេដ្ឋារចនាសម្ព័ន្ធជនបទនៅកម្ពុជា ច្រើនជួបបញ្ហាដូចជា ផ្លូវថ្នល់មិនគ្រប់គ្រាន់ និង កង្វះការថែទាំផ្លូវ ជាដើម ។ បន្ទុកចំណាយក្នុងផ្នែកនេះ កាន់តែធ្ងន់ធ្ងរឡើងទៀត ដោយសារការបង់ប្រាក់កំរៃក្រៅផ្លូវការនៅពេលដឹកជញ្ជូនទំនិញ ។ |
| **ការបង្កើនហិរញ្ញប្បទាន** | ការបង្កើនកំចីកសិកម្ម គឺជាកិច្ចខំប្រឹងប្រែងមួយដើម្បីសំរាលផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចពិភពលោក ។ កំចី ជួយផ្ដល់ប្រាក់បន្ថែមសំរាប់ការពង្រីកកសិកម្ម ។ សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្នើឱ្យ ក្រសួងហិរញ្ញវត្ថុ ធ្វើការលើកទឹកចិត្តធនាគារពាណិជ្ជ ក្នុងការប្រើកំចីដើម្បីជំរុញកំណើនសេដ្ឋកិច្ចជាតិ ។ តបនឹងសំណើរបស់រដ្ឋាភិបាល ធនាគារអេស៊ីលីដា បានបញ្ជាក់ថា នឹងបង្កើនកំចីចំពោះវិស័យកសិកម្មដល់ទៅ ១១៤លានដុល្លារ នៅឆ្នាំ២០០៩ ធៀបនឹង ៥៦,៥លានដុល្លារ នៅឆ្នាំ២០០៨ ។ |
| **ការពង្រីក ការស្រាវជ្រាវ និងអភិវឌ្ឍន៍** | របាយការណ៍របស់ធនាគារពិភពលោក ឆ្នាំ២០០៩ បានឱ្យដឹងថា តាមបទពិសោធន៍កន្លងមក វិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម និងលើផ្លូវជនបទ មានអត្រាផ្ដល់ផលត្រឡប់ខ្ពស់បំផុត សំរាប់ការកាត់បន្ថយភាពក្រីក្រ ។ នៅប្រទេសចិន ការបង្កើនចំណាយ ១% ទៅលើការស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម នឹងបង្កើន ផសស វិស័យកសិកម្មបាន 0.0៨៥% ក្នុងមនុស្សម្នាក់ៗ ។ កំណើន ផសស វិស័យកសិកម្ម នេះ នឹងកាត់បន្ថយចំនួនជនក្រីក្របាន 0.១% ។ |
| **ការបង្កើន ផលិតភាព និងប្រសិទ្ធភាព នៃការប្រើប្រាស់ធាតុចូល** | របាយការណ៍របស់ធនាគារពិភពលោក ឆ្នាំ២០០៩ បានបង្ហាញថា ដីខ្វះជីជាតិ គឺជាឧបសគ្គចំបងដល់ផលិតកម្មនៅតំបន់វាលទំនាបភាគច្រើន ហើយបញ្ហានេះអាចដោះស្រាយបានដោយការប្រើបច្ចេកវិទ្យាគ្រប់គ្រងជី និងជីដ៏សមស្រប ។ ការប្រើប្រាស់ជីកសិកម្មនៅកម្ពុជា មានកំរិតទាប និងមិនសូវមានប្រសិទ្ធភាពទេ បើធៀបនឹងប្រទេសជិតខាង ។ ការប្រើប្រាស់ជីកសិកម្ម អាចបង្កើនទិន្នផលស្រូវបានយ៉ាងច្រើនទៀត ។ កំណើនការប្រើប្រាស់ជីកសិកម្ម ១% អាចបង្កើនទិន្នផលស្រូវប្រាំងបាន 0,២២% និងស្រូវវស្សា 0,២៧% ។ |
| **គ្រឿងលើកទឹកចិត្តទីផ្សារ** | កម្ពុជា ជាប្រទេសផលិត និងនាំចេញស្រូវដ៏សំខាន់មួយនៅក្នុងតំបន់ ហើយអ្នកនាំចូលស្រូវចំបងៗគឺមាន ប្រទេសនៅតំបន់មជ្ឈិមបូព៌ា និង ប្រទេសនៅអាហ្វ្រិកមួយចំនួនក្នុងតំបន់ខាងត្បូងវាលខ្សាច់សាហារ៉ា ។ កិច្ចព្រមព្រៀងពហុភាគី និងទ្វេភាគីរវាងអ្នកនាំចេញ និងអ្នកនាំចូល អាចជាមធ្យោបាយជឿនលឿនមួយសំរាប់កាត់បន្ថយភាពមិនប្រាកដប្រជាក្នុងពាណិជ្ជកម្មអន្តរជាតិនៃស្រូវអង្ករ ។ កម្ពុជា ក៏គួរផ្ដោតផងដែរ លើការធ្វើចំរុះកម្មច្រកទីផ្សារចូលទៅតំបន់អាស៊ីបូព៌ា ដែលជាទីផ្សារដ៏ធំសំរាប់ដំណាំឧស្សាហកម្ម ដូចជា កៅស៊ូ ដំឡូងឈើ និង ពោត ជាដើម ។ ម្យ៉ាងទៀត ផលិតផលកសិកម្មភាគច្រើន បាននាំចេញពីកម្ពុជាក្នុងលក្ខណៈជាទំនិញគ្មានកែច្នៃ ។ ដូច្នេះ ដើម្បីបន្ថែមតំលៃលើទំនិញកសិកម្ម រដ្ឋាភិបាលគួរតំរង់ទិស វិនិយោគទៅខាងបច្ចេកវិទ្យាក្រោយការប្រមូលផល ដូចជា ប្រព័ន្ធសំរាប់កិន កែច្នៃ និង ស្តុកទុក ជាដើម ។ |
| **ការកែលំអបរិយាកាសវិនិយោគ និងពាណិជ្ជកម្ម** | ដើម្បីកែលំអបរិយាកាសពាណិជ្ជកម្ម និងអាជីវកម្ម វិនិយោគិនទាំងអស់ក្នុងកសិអាជីវកម្ម គួររួមគ្នាជាក្រុម និងធ្វើការជាមួយរដ្ឋាភិបាល ជាពិសេស ក្រសួងពាណិជ្ជកម្ម ។ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា គឺជាគំរូដ៏ល្អមួយ ។ វិមជ្ឈការ និង ការផ្ដល់អំណាចដល់អាជ្ញាធរមូលដ្ឋាន និងតំបន់ គឺគួរធ្វើឡើង ដើម្បីដោះស្រាយបញ្ហាផ្សេងៗក្នុងតំបន់ ។ ការអនុម័ត និងអនុវត្តច្បាប់រៀបចំអង្គការ អាចជាជំហានមួយដ៏សំខាន់សំដៅកាត់បន្ថយបន្ទុកចំណាយខាងរដ្ឋបាល និងការិយាល័យធិបតេយ្យ ដែលប្រជាជនកំពុងប្រឈមមុខ ជាពិសេសអ្នកនៅជនបទ ។ |

** ប្រភព៖ របាយការណ៍របស់ ធនាគារពិភពលោក (២០០៩) ស្ដីពី ការរក្សាកំណើនលឿន នៅក្នុងបរិយាកាសប្រឈម (ឯកសារជំនួញស្មារតីស្ដីពីសេដ្ឋកិច្ចប្រទេសកម្ពុជា)*